# ព្រះ
# ត្រៃបិដកបាលី
នឹង
សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក
ចតុត្ថភាគ
# ២៣

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៥០៥

សុត្តន្តបិដក

មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកំ

ចតុត្ថភាគ

២៣

ព.ស. ២៥១៤

(៦៦) អតិន្តិណតំ និស្សាយ តិន្តិណតា បហាតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ ហេតុ តិន្តិណោ អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន តិន្តិណោ អស្សំ អត្តាបិ មំ ឧបវទេយ្យ តិន្តិណ-បច្ចយា អនុវិច្ចបិ មំ វិញ្ញូ គរហេយ្យុំ តិន្តិណបច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា តិន្តិណ-បច្ចយា ឯតទេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ យទិទំ តិន្តិណតា យេ ច តិន្តិណបច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា អតិន្តិណ-ស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ





(៦៦) ត្រង់ពាក្យថា ព្រោះពឹងអាស្រ័យសេចក្ដីមិនគ្រាច់គ្រាញ់ គឺមិនតិន្តា ទើបលះបង់សេចក្ដីគ្រាច់គ្រាញ់ គឺតិន្តាចេញផ្លូវខ្លួននេះ គប្បីភិក្ខុបានពោលហើយ ដោយប្រការដូច្នេះ គឺពាក្យនេះដែលគប្បីពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អញគប្បីជាអ្នកមានសេចក្ដីគ្រាច់គ្រាញ់គឺតិន្តា ព្រោះហេតុសំយោជនៈទាំងឡាយណា អញគប្បីបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្ដាច់បង់នូវសំយោជនៈទាំងនោះចេញហើយ មួយវិញទៀត បើកាលអញ ជាអ្នកមានសេចក្ដីគ្រាច់គ្រាញ់ គឺតិន្តាហើយ សូម្បីខ្លួនឯង គឺខ្លួនគប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្ដីគ្រាច់គ្រាញ់គឺតិន្តា ទាំងអ្នកប្រាជ្ញដែលបានពិចារណាហើយ ៗ ហើយ គប្បីតិះដៀលបាន ព្រោះហេតុសេចក្ដីគ្រាច់គ្រាញ់គឺតិន្តា លុះទម្លាយរាងកាយទៅខាងមុខ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទុគ្គតិគឺឋានអបាយគប្បីប្រាថ្នា ព្រោះហេតុសេចក្ដីគ្រាច់គ្រាញ់ គឺតិន្តា ធម្មជាតនុ៎ះហៅថាសំយោជនៈ ធម្មជាតនុ៎ះ ហៅថានីវរណៈ គឺសេចក្ដីគ្រាច់គ្រាញ់គឺតិន្តាហ្នឹងឯង មួយវិញទៀត អាសវៈទាំងឡាយណា ដែលមានសេចក្ដីចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្ដីគ្រាច់គ្រាញ់គឺតិន្តា អាសវៈដែលមានសេចក្ដីចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដី

អច្ឆរាចេសំ ឆិសក្ខាយ ចំនុះចេសោ បហាតព្វាតិ

ឥតិ យត្តំ វុត្តំ ឥធមេតំ បដិច្ច វុត្តំ ។

(៦៨) អញ្ញាទុតាយាសំ ចំសក្ខាយ ទោកាទុតាយា-

ចេសា បហាតព្វាតិ ឥតិ ទោ ជហតំ វុត្តំ ភិក្ខវេត្តំ

បដិច្ច វុត្តំ ឥធ ករោបតិ អរិយសច្ចានោ ឥតិ បដិ-

សញ្ញាត្តិ យេសំ ទោ អយំ សញ្ញោជនានំ ហោតុ

ទោកាទុតាយាសី អស្សុំ ចេសាហំ សញ្ញោជនានំ បហា-

នាយ សមុច្ឆេទាយ បដិបន្នោ អហោសិ ទោ បច

ទោកាទុតាយាសី អស្សុំ អត្ថាបិ មំ ឱបចេយ្យ

ទោកាទុតាយាសម្បត្តិយា អនុវិទ្ធ វិញ្ញូ ករោហយុំ

ទោកាទុតាយាសម្បត្តិយា ការយស្ស ចេតា បាទ-



ត្រង់ពាក្យ និងមិនគិតរាប់រកនេះ ពាក្យណា ដែលរកជាតិការណ៍ហើយថា
ព្រោះអាស្រ័យសេចក្តីត្រេកត្រអាល និង មិនគិត ទើបលះបង់សេចក្តីត្រេក-
ត្រអាល និងគិតរកផ្លូវខុស ពាក្យនេះ ជាតិការណ៍ហើយ ព្រោះ
អាស្រ័យហេតុនុ៎ះឯង ។

(៦៩) ត្រង់ពាក្យថា ព្រោះអាស្រ័យ នូវសេចក្តីមិនជាប់ទៀតទាត់
និងមិនគ្រោង ទើបលះបង់សេចក្តីជាប់ទៀតទាត់ និង សេចក្តីគ្រោងចេញ
ផ្លូវខុសនេះ ជាតិការណ៍ហើយ សំដៅប្រកាសផ្លូវខុស ក៏ពាក្យនេះដែល
ជាតិការណ៍ហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំង ឡាយ
សាវ័កក្នុងសាសនានេះ រមែងគិតរកផ្លូវខុសថា កាត្តាកញ្ញ ជាផ្លូវនាំ
សេចក្តីជាប់ទៀតទាត់ និង សេចក្តីគ្រោង ព្រោះដាក់ចិត្តយ៉ាងនេះ ហាក់-
ប្រាថ្នាណា កាត្តាកញ្ញ ជាសេចក្តីឱ្យត្រូវ ដើម្បីលះបង់ ដើម្បីផ្តាច់ផ្តិលហេតុ-
ផលរបស់វាចេញហើយ មួរីងទៀត ទើបកាត្តាកញ្ញ ជាផ្លូវនាំសេច-
ក្តីជាប់ទៀតទាត់ និងសេចក្តីគ្រោងហើយ ស្តាប់នូវនោះ គឺតម្រិះរៀល
នូវនោះចុះ ព្រោះសេចក្តីជាប់ទៀតទាត់ និង សេចក្តីគ្រោង ទាំងអស់
ប្រាថ្នាដែលបានគិតរកឃើញ ។ ហើយ ក៏តម្រិះរៀលចុះ ព្រោះ
សេចក្តីជាប់ទៀតទាត់ និង សេចក្តីគ្រោង សុះទម្លាយកាយ ទាំងមុខ

រណា ។ ឧប្បត្តិ ពាធិកាថា អសប្បដិឃោ ធម្មោ សប្បដិឃស្ស
ធម្មស្ស ។ល។ សញ្ញោជនំ ឋតិ និវរណំ យេនិដំ
អសប្បដិឃោ ធម្មោ សប្បដិឃស្ស ធម្មស្ស
ឧប្បជ្ជេយ្យ អាសវ វិមានបរិញ្ញោ អសប្បដិ-
ឃស្ស ធម្មស្ស ។ល។ អាសវ វិមានបរិញ្ញោ ១
អោត្ថិ អសប្បដិឃស្ស និស្សាយ អសប្បដិឃោ
បហានភោគ នតិ យត្ថ ឋត្ថ នតេថតំ បដិច្ច ឋត្ថ ។

[៦៦] អចតិមានំ និស្សាយ អតិមានោ បហា-
នភោគ នតិ ហេ បលតំ ឋត្ថ ករណតំ បដិច្ច ឋត្ថំ
នង តបាបតិ អរិយសច្ចកោ នតិ បដិសញ្ញោតិ



អន្តរាយពីសេចក្ដីស្ងប់ស្ងាត់ ឧប្បត្តិ និងមានប្រាកដ ព្រោះហេតុសេចក្ដី
ចង្អៀតចង្អល់ គឺសេចក្ដីក្រោធ អប្បដិឃធម៌ ហៅថាសប្បដិឃៈ អប្បដិឃ
ធម៌ ហៅថានិវរណៈ គឺ សេចក្ដីចង្អៀតចង្អល់ គឺ សេចក្ដីក្រោធហ្នឹង
ឯង ម្យ៉ាងទៀត ការសោះចាំងព្យាយាម ដែលមានសភាពចង្អៀតចង្អល់
ក្រពាល់ក្រពាយ កើតឡើង ព្រោះហេតុសេចក្ដីចង្អៀតចង្អល់ គឺ
សេចក្ដីក្រោធ ការសោះដែលមានសភាពចង្អៀតចង្អល់ ក្រពាល់ក្រពាយ
ទាំងនោះ មិនមានផលចំពោះសត្វ ដែលជាគ្រឿងមានសេចក្ដីចង្អៀត-
ចង្អល់ គឺ សេចក្ដីក្រោធយ៉ាងនេះ ពាក្យណា ដែលគប់ជាធម្មតា
ហើយថា ព្រោះអាស្រ័យនូវសេចក្ដីចង្អៀតចង្អល់ គឺ សេចក្ដីមិនក្រោធ
ហើយលះបង់សេចក្ដីចង្អៀតចង្អល់ គឺ សេចក្ដីក្រោធចេញផ្លូវខ្លះ ពាក្យ
នេះ គួរជាធម្មតាការហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[៦៦] ត្រង់ពាក្យថា ព្រោះអាស្រ័យ នូវសេចក្ដីមិនមើលងាយនេ
ទើបលះបង់សេចក្ដីមើលងាយផ្លូវខ្លះនេះ គប់ធម្មតាការហើយដោយ
ប្រការផ្លូវខ្លះ គឺពាក្យនេះ ដែលគប់ធម្មតាការហើយ ព្រោះអាស្រ័យ
ហេតុថា ម្នាលភិក្ខុទាំង អរិយសាវ័កក្នុងសាសនានេះ រមែងពិចារណា

យេសំ នោ អយំ សញ្ញោជនានំ ហេតុ អតិមានី អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន អតិមានី អស្សំ អត្តាបិ មំ ឧបវទេយ្យ អតិមានបច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ អតិមានបច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា អតិមានបច្ចយា ឯតំ ខោ បន សញ្ញោជនំ ឯតំ និវរណំ យទិទំ អតិមានោ យេ ច អតិមានបច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា អនតិមានិស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ អនតិមានំ និស្សាយ អតិមានោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមេ ខោ គហបតិ អដ្ឋ ធម្មា



ដូច្នេះថា អាត្មាអញ ជាអ្នកមានសេចក្ដីមើលងាយនេះ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញ បានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្ដាច់បង់សំយោជនៈទាំងនោះចេញហើយ មួយទៀត បើអាត្មាអញ ជាអ្នកមានសេចក្ដីមើលងាយនោះហើយ ស្លួតខ្លួនឯង គឺគប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្ដីមើលងាយ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗ ហើយ គប្បីតិះដៀលបាន ព្រោះហេតុសេចក្ដីមើលងាយនេះ លុះបែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសេចក្ដីមើលងាយ ធម្មជាតនុ៎ះ ហៅថាសំយោជនៈ ធម្មជាតនុ៎ះ ហៅថានីវរណៈ គឺ សេចក្ដីមើលងាយហ្នឹងឯង មួយទៀត អាសវៈទាំងឡាយណា ដែលធ្វើសេចក្ដីចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្ដីមើលងាយនេះ អាសវៈដែលធ្វើសេចក្ដីចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដីមើលងាយ យ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យ នូវសេចក្ដីមិនមើលងាយនេះ ទើបលះបង់សេចក្ដីមើលងាយចេញផ្លូវនុ៎ះ ពាក្យនេះ តថាគត បានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។ ម្នាលគហបតី ធម៌ទាំង ៨

សង្ខិត្តេន វុត្តា វិត្ថារេន អវិភត្តា យេ អរិយស្ស វិនយេ វោហារាយ វោហារសមុច្ឆេទាយ សំវត្តន្តិ ន ត្វេវ តាវ គហបតិ អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារស្ស សមុច្ឆេទោ ហោតីតិ ។ យថា កថំ បន ភន្តេ អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារសមុច្ឆេទោ ហោតិ សាធុ មេ ភន្តេ ភគវា តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារស្ស សមុច្ឆេទោ ហោតីតិ ។ តេនហិ គហបតិ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ ពោតលិយោ គហបតិ ភគវតោ បច្ចស្សោសិ ។

(៤៧) ភគវា ឯតទវោច សេយ្យថាបិ គហបតិ កុក្កុរោ ជិឃច្ឆាទុព្វល្យបរេតោ គោឃាតកសូនំ បច្ចុបដ្ឋិតោ អស្ស តមេនំ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា អដ្ឋិកង្កលំ សុនិក្កន្តំ និក្កន្តំ និម្មំសំ លោហិតមក្ខិតំ ឧបសុម្ភេយ្យ(១)

---

១ ឧបសុម្ភេយ្យាតិ [illegible] ។ [illegible]



ណា ដែលប្រព្រឹត្តទៅ ដើម្បីលះបង់ ដើម្បីផ្តាច់បង់ជំនួញ ក្នុងអរិយវិន័យ ធម៌ទាំង ៨ នេះឯង តថាគតពោលហើយ ដោយសង្ខេប មិនបានចែក ដោយពិស្តារទេ ម្នាលគហបតី ការផ្តាច់បង់ជំនួញ សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ មិនមានត្រឹមប៉ុណ្ណោះទេ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះការផ្តាច់បង់ជំនួញ សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យនោះ តើដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន ការផ្តាច់បង់ជំនួញ សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ យ៉ាងណា សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ យ៉ាងនោះ ដល់ខ្ញុំព្រះអង្គឲ្យបាន ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរស្តាប់ ចូរយកចិត្តទុកដាក់ដោយប្រពៃចុះ តថាគតនឹងសំដែងឲ្យស្តាប់ ។ ពោតលិយគហបតី ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(៤៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ដូចសុនខ ដែលអស់កម្លាំង ព្រោះសេចក្តីឃ្លានគ្របសង្កត់ ក៏ដើរចូលទៅកាន់ទីសម្លាប់គោសាច់លក់ របស់គោឃាតកៈ ឯគោឃាតកៈក្តី កូនឈ្នួលរបស់គោឃាតកៈក្តី ដែលឈ្លាស បោះគល់ឆ្អឹងដែលគេដួះសាច់ចេញស្អាត អស់មានសាច់ គ្រាន់តែប្រឡាក់ដោយឈាម ទៅឲ្យឆ្កែនោះ

តំ កឹ មញ្ញសិ គហបតិ អបិ នុ សោ កុក្កុរោ អទុំ អដ្ឋិកង្កលំ សុនិក្កន្តំ និក្កន្តំ និម្មំសំ លោហិតមក្ខិតំ បលេហន្តោ(១) ជិឃច្ឆាទុព្ពល្យំ បដិវិនេយ្យាតិ ។ នោ ហេតំ ភន្តេ តំ កិស្ស ហេតុ អទុំ ហិ ភន្តេ អដ្ឋិកង្កលំ សុនិក្កន្តំ និក្កន្តំ និម្មំសំ លោហិតមក្ខិតំ យាវទេវ ច បន សោ កុក្កុរោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា យាយំ ឧបេក្ខា នានត្តា នានត្តសិតា តំ អភិនិវជ្ជេត្វា យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា យត្ថ សព្វសោ លោកាមិសូបាទានា អបរិសេសា និរុជ្ឈន្តិ តមេវ ឧបេក្ខំ ភាវេតិ ។

១ ម. បលិហន្តោ ។



ម្នាលគហបតី អ្នកសំគាល់សេចក្ដីនោះជាដូចម្ដេច ឆ្កែនោះកាលលិទ្ធនូវឆ្អឹងជំនីរ ដែលគេចិតសាច់ចេញស្អាត ឥតមានសាច់ ប្រឡាក់តែប្រឡាក់ដោយឈាម នឹងបន្ទាបង់សេចក្ដីស្រេកឃ្លាន ព្រោះការឃ្លានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ការបន្ទាបង់នូវសេចក្ដីស្រេកឃ្លាន ព្រោះការឃ្លាននុ៎ះ មិនបានទេ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ចង្កូមឆ្អឹងនោះ ដែលគេចិតសាច់ចេញស្អាត ឥតមានសាច់ ប្រឡាក់តែប្រឡាក់ដោយឈាម ឆ្កែនោះ ជាសត្វត្រូវតែមានចំណែកនៃសេចក្ដីលំបាកកាយលំបាកចិត្ត ប៉ុណ្ណោះឯង ។ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយ មានឧបមាដោយចង្កូមឆ្អឹង មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនក្រៃលែងក្នុងកាមទាំងនេះ យ៉ាងនេះឯង អរិយសាវក ឃើញសេចក្ដីនេះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ ក៏លះបង់នូវឧបេក្ខា (ក្នុងកាមគុណ) ដែលមានសភាពផ្សេងគ្នា អាស្រ័យនូវអារម្មណ៍មានសភាពផ្សេងគ្នា ហើយចំរើនឧបេក្ខា(១) ដែលមានសភាពតែមួយ អាស្រ័យនូវអារម្មណ៍មានសភាពតែមួយ គឺឧបេក្ខា(២) ជាទីរលត់នៃឧបាទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

១-២ បានដល់ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។

[៤៨] សេយ្យថាបិ គហបតិ គិជ្ឈោ វា កង្កោ វា(១) កុលលោ វា មំសបេសិំ អាទាយ(២) ឧឌ្ឌីយេយ្យ(៣) តមេនំ គិជ្ឈាបិ កង្កាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតច្ឆេយ្យុំ វិភជេយ្យុំ តំ កិំ មញ្ញសិ គហបតិ សចេ សោ គិជ្ឈោ វា កង្កោ វា កុលលោ វា តំ មំសបេសិំ ន ខិប្បមេវ បដិនិស្សជ្ជេយ្យ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ(៤) មរណមត្តំ វា ទុក្ខន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ មំសបេសូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា យាយំ ឧបេក្ខា នានត្តា នានត្តសិតា តំ អភិនិវជ្ជេត្វា យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា យត្ថ សព្វសោ លោកាមិសុបាទានា អបរិសេសា និរុជ្ឈន្តិ តមេវូបេក្ខំ ភាវេតិ ។

១ ម. ឧ. កង្កោ វា ។ ២ ម. ឧ. មំសបេសឹ អាទាយ ។ ៣ ម. ឧ. ឧឌ្ឌីយេយ្យ ។ ៤ ម. ឧ. និគច្ឆេយ្យ ។



[៤៨] ម្នាលគហបតី ដូចជាសត្វត្មាត រឺក្អែកក្រលាយ ឬខ្លែងស្ទាំង ពាំនាំដុំសាច់ហើរទៅ មានពួកត្មាតផង ពួកក្អែកក្រលាយផង ពួកខ្លែងស្ទាំងផង ហើរដេញតាមសត្វត្មាតជាដើមនោះ ចឹកជល្លែងដណ្តើមយក ម្នាលគហបតី អ្នកសំគាល់សេចក្តីនោះជាដូចម្តេច បើសត្វត្មាត រឺក្អែកក្រលាយ ឬខ្លែងស្ទាំងនោះ មិនលះបង់ដុំសាច់នោះ ដោយឆាប់ទេ ក៏ត្មាតជាដើមនោះ នឹងដល់នូវសេចក្តីស្លាប់ ឬ សេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះដុំសាច់នោះជាហេតុ មែនឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយ មានឧបមាដោយដុំសាច់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនក្រៃពេក ក្នុងកាមទាំងនេះ យ៉ាងនេះឯង អរិយសាវក ឃើញសេចក្តីនេះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ ក៏លះបង់នូវឧបេក្ខាដែលមានសភាពផ្សេងគ្នា អាស្រ័យនូវអារម្មណ៍ មានសភាពផ្សេងគ្នា ចម្រើននូវឧបេក្ខាដែលមានសភាពតែមួយ អាស្រ័យនូវអារម្មណ៍ មានសភាពតែមួយ និងឧបេក្ខាជាទីរលត់ នៃឧបាទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

(៤៩) សេយ្យថាបិ គហបតិ បុរិសោ អាទិត្តំ តិណុក្កំ អាទាយ បដិវាតំ គច្ឆេយ្យ តំ កឹ មញ្ញសិ គហបតិ សចេ សោ បុរិសោ តំ អាទិត្តំ តិណុក្កំ ន ខិប្បមេវ បដិនិស្សជ្ជេយ្យ តស្ស សា អាទិត្តា តិណុក្កា ហត្ថំ វា ទហេយ្យ(១) ពាហុំ វា ទហេយ្យ អញ្ញតរំ វា អញ្ញតរំ វា អង្គបច្ចង្គំ វា(២) ទហេយ្យ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ តិណុក្កូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ។បេ។ តមេវ ឧបេក្ខំ ភាវេតិ ។

(៥០) សេយ្យថាបិ គហបតិ អង្គារកាសុ សាធិកបោរិសា បុណ្ណា អង្គារានំ វីតច្ចិកានំ វីតធូមានំ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ តមេនំ ទ្វេ ពលវន្តោ បុរិសា នានាពាហាសុ គហេត្វា អង្គារកាសុំ ឧបកឌ្ឍេយ្យុំ

១ ម. យ. ទហេយ្យ ។ ២ ម. អញ្ញតរំ វា អង្គបច្ចង្គំ ។



(៤៩) ម្នាលគហបតី ដូចជាបុរសកាន់នូវគប់ស្មៅដែលឆេះភ្លើងនេះដើរច្រាសខ្យល់ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះជាដូចម្តេច បើបុរសនោះ មិនលះបង់គប់ស្មៅដែលឆេះភ្លើងនោះ ដោយឆាប់ទេ គប់ស្មៅដែលឆេះភ្លើងនោះ នឹងរលាកនូវដៃក្តី ឬ រលាកនូវអវយវៈតូចធំណាមួយ បុរសនោះ នឹងដល់នូវសេចក្តីស្លាប់ ឬ សេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះគប់ស្មៅដែលឆេះភ្លើងនោះ ជាហេតុដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយ មានឧបមាដោយគប់ស្មៅ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោស មានច្រើនក្រៃលែងក្នុងកាមទាំងនេះ យ៉ាងនេះឯង អរិយសាវក ឃើញសេចក្តីនេះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះ ។ បេ ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

(៥០) ម្នាលគហបតី ដូចជារណ្តៅរងើកភ្លើង មានជម្រៅមួយធំជាងបុរស ពេញដោយរងើកភ្លើង ឥតមានអណ្តាត ឥតមានផ្សែង កាលនោះ មានបុរសម្នាក់មានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដើរមក (កាន់រណ្តៅនោះ) មានបុរសពីរនាក់កំលាំងខ្លាំង ចាប់បុរសនោះ ត្រង់កំភួនដៃម្នាក់ម្ខាង ទាញទម្លាក់

តំ កឹ មញ្ញសិ គហបតិ អបិ នុ សោ បុរិសោ ឥតិ ចិតិ ចេវ កាយំ សន្នាមេយ្យាតិ(១) ។ ឯវំ ភន្តេ(២) តំ កិស្ស ហេតុ វិទិតំ ហិ ភន្តេ តស្ស បុរិសស្ស អមុំ(៣) អហំ អង្គារកាសុំ បបតិស្សាមិ តតោនិទានំ មរណំ វា និគច្ឆិស្សាមិ(៤) មរណមត្តំ វា ទុក្ខន្តិ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ អង្គារកាសូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

(៥១) សេយ្យថាបិ គហបតិ បុរិសោ សុបិនកំ បស្សេយ្យ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកំ សោ បដិពុទ្ធោ ន កិញ្ចិ បស្សេយ្យ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ សុបិនកូបមា កាមា វុត្តា ភគវតា ពហុទុក្ខា

១ ម. ចនាមេយ្យាតិ ។ ២ ម. ឱ. ឯវំ ភន្តេ ។ ៣ ម. អមុញ្ញ ។ ៤ ម. និគច្ឆេ ។



ទៅក្នុងរណ្តៅ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច តើបុរសនោះ គួរបង្អោនកាយ (ទៅកាន់រណ្តៅ) នោះជួនខ្វះ ជួនខ្វេះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសនោះ មិនគួរបង្អោនកាយទៅឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះបុរសនោះដឹងច្បាស់ថា បើអាត្មាអញ នឹងធ្លាក់រណ្តៅរងើកភ្លើងនេះ អាត្មាអញ នឹងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតស្លាប់ ព្រោះរណ្តៅរងើកភ្លើងនោះជាហេតុ ។ ម្នាលគហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយ មានឧបមាដោយរណ្តៅរងើកភ្លើង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានក្រៃលែងប្រមាណ ក្នុងកាមទាំងនេះ យ៉ាងនេះឯង អរិយសាវ័ក ឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ ។ បេ ។ ក៏ចំរើននូវឧបេក្ខានោះឯង ។

(៥១) ម្នាលគហបតី ដូចជាបុរស យល់សប្តិឃើញអារាមជាទីសប្បាយ ព្រៃជាទីសប្បាយ ផែនដីជាទីសប្បាយ និងស្រះបោក្ខរណីជាទីសប្បាយ លុះបុរសនោះភ្ញាក់ឡើង មិនឃើញអ្វីមួយឡើយ ម្នាលគហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយ មានឧបមាដោយយល់សប្តិ មានទុក្ខ

ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

(៨២) សេយ្យថាបិ គហបតិ បុរិសោ យាចិតកំ ភោគំ យាចិត្វា យានំ ពោរោសេយ្យំ(១) បវរមណិកុណ្ឌលំ សោ តេហិ យាចិតកេហិ ភោគេហិ បុរក្ខតោ បរិវុតោ អន្តរាបណំ បដិបជ្ជេយ្យ តមេនំ ជនោ ទិស្វា ឯវំ វទេយ្យ ភោគី វត ភោ បុរិសោ ឯវំ កិរ ភោគិនោ ភោគានិ ភុញ្ជន្តីតិ តមេនំ សាមិកា យត្ថ យត្ថេវ បស្សេយ្យុំ តត្ថ តត្ថេវ សាមិកា(២) សកំ ហរេយ្យុំ តំ កឹ មញ្ញសិ គហបតិ អលំ នុ ខោ តស្ស បុរិសស្ស អញ្ញថត្តាយាតិ ។ នោ ហេតំ ភន្តេ(៣) តំ កិស្ស ហេតុ សាមិនោ ហិ ភន្តេ សកំ ហរន្តីតិ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ

១ ឱ. បាន៍ យោគ្គបោរោសេយ្យំ ។ ម. បាន៍ ក យោគ្គបោរោសេយ្យំ ។ ២ ឱ. សាមិកានិ សកានិ ។ ៣ ឱ. ម. ឯវំ ភន្តេ ។



ច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសនេះមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនេះឯង ។ បេ ។ គឺចម្រើននូវឧបេក្ខានោះឯង ។

(៨២) ម្នាលគហបតី ដូចជាបុរស ខ្ចីទ្រព្យគេជារបស់បណ្តោះអាសន្ន គឺយានមណីនិងកុណ្ឌល (ក្រវិលប្រដាប់ត្រចៀក) ដ៏ប្រសើរ ហើយ ឡើងកាន់យាន បុរសនោះ បានប្រដាប់តាក់តែងដោយទ្រព្យជារបស់ខ្ចីគេ ចន្លោះកណ្តាលផ្សារទាំងនោះ ដើរទៅកាន់កណ្តាលផ្សារ ពួកជនបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា អើហ្ន៎ បុរសនេះ មានភោគសម្បត្តិច្រើនណាស់ ចុះឃើញ ពួកជនអ្នកមានភោគសម្បត្តិ រមែងបរិភោគសម្បត្តិយ៉ាងនេះឯង លុះពួកជនជាម្ចាស់ទ្រព្យឃើញបុរសនោះក្នុងទីណា ៗ ក៏នាំយកទ្រព្យ ដែលជារបស់ខ្លួនក្នុងទីនោះទៅ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច បុរសនោះ គួរកាន់អន់ចិត្តឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះ មិនគួរនឹងកាន់អន់ចិត្តទេ ។ ដំណើរនោះព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះពួកជនជាម្ចាស់ទ្រព្យ នាំយកទ្រព្យដែលជារបស់ខ្លួនទៅ ។ ម្នាលគហបតី អរិយសាវ័ក តែង

ឥតិ បដិសញ្ចិក្ខតិ យាចិតកូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

(៤៣) សេយ្យថាបិ គហបតិ គាមស្ស វា និគមស្ស វា អវិទូរេ តិព្វោ វនសណ្ឌោ តត្រស្ស រុក្ខោ សម្បន្នផលោ ច ឧបបន្នផលោ ច ន ចស្សុ កានិចិ ផលានិ ភូមិយំ បតិតានិ អថ បុរិសោ អាគច្ឆេយ្យ ផលត្ថិកោ ផលគវេសី ផលបរិយេសនំ ចរមានោ សោ តំ វនសណ្ឌំ អជ្ឈោគាហេត្វា តំ រុក្ខំ បស្សេយ្យ សម្បន្នផលញ្ច ឧបបន្នផលញ្ច តស្ស ឯវមស្ស អយំ ខោ រុក្ខោ សម្បន្នផលោ ច ឧបបន្នផលោ ច នត្ថិ ច កានិចិ ផលានិ ភូមិយំ បតិតានិ ជានាមិ ខោ បនាហំ រុក្ខំ អភិរុហិតុំ(១) យន្នូនាហំ ឥមំ រុក្ខំ អភិរុហិត្វា(២) យាវទត្ថញ្ច ខាទេយ្យំ ឧច្ឆង្គញ្ច បូរេយ្យន្តិ សោ តំ រុក្ខំ អភិរុហិត្វា(៣) យាវទត្ថញ្ច ខាទេយ្យ

១ ម. ឱ. អារោហិតុំ ។ ២-៣ ម. អារោហិត្វា ។



ពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយរបស់ខ្ចីគេ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនក្រៃលែង ក្នុងកាមទាំងនេះ យ៉ាងនេះឯង ។ បេ ។ គឺចម្រើននូវឧបេក្ខានោះឯង ។

(៤៣) ម្នាលគហបតី ដូចជាដងព្រៃស្អុក នៅជិតស្រុកឬនិគម មានដើមឈើក្នុងព្រៃនោះ ជាឈើមានផ្លែផ្លួមផង មានផ្លែដ៏ច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ទើបមានបុរសម្នាក់ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែ ត្រាច់ទៅស្វែងរកផ្លែ ក៏ដើរមកដល់ បុរសនោះ ដើរចូលទៅកាន់ដងព្រៃនោះ ឃើញដើមឈើនោះ មានផ្លែផ្លួមផង មានផ្លែដ៏ច្រើនផង ទើបបុរសនោះគិតយ៉ាងនេះថា ឈើនេះឯង មានផ្លែផ្លួមផង មានផ្លែដ៏ច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ឯអាត្មាអញ ក៏ចេះឡើងដើមឈើដែរ បើដូច្នោះ មានតែអាត្មាអញឡើងកាន់ដើមឈើនេះ ហើយទំពាស៊ីត្រាតែឆ្អែតផង ដាក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏ឡើងកាន់ដើមឈើនោះ ទំពាស៊ីត្រាតែឆ្អែតផង

ឧច្ឆង្គញ្ច បូរេយ្យ អថ ទុតិយោ បុរិសោ អាគច្ឆេយ្យ ផលត្ថិកោ ផលគវេសី ផលបរិយេសនំ ចរមានោ តិណ្ហំ កុធារឹ(១) អាទាយ សោ តំ វនសណ្ឌំ អជ្ឈោគាហេត្វា តំ រុក្ខំ បស្សេយ្យ សម្បន្នផលញ្ច ឧបបន្នផលញ្ច តស្ស ឯវមស្ស អយំ រុក្ខោ សម្បន្នផលោ ច ឧបបន្នផលោ ច នត្ថិ ច កានិចិ ផលានិ ភូមិយំ បតិតានិ ន ខោ បនាហំ ជានាមិ រុក្ខំ អារោហិតុំ យន្នូនាហំ ឥមំ រុក្ខំ មូលតោ ឆេត្វា យាវទត្ថញ្ច ខាទេយ្យំ ឧច្ឆង្គញ្ច បូរេយ្យន្តិ សោ តំ រុក្ខំ មូលតោ ឆិន្ទេយ្យ តំ កឹ មញ្ញសិ គហបតិ អមុកោ សោ(២) បុរិសោ បឋមំ រុក្ខំ អារូឡ្ហោ សចេ សោ ន ខិប្បមេវ ឱរោហេយ្យ តស្ស សោ រុក្ខោ បបតន្តោ ហត្ថំ វា ភញ្ជេយ្យ បាទំ វា ភញ្ជេយ្យ អញ្ញតរំ វា អង្គបច្ចង្គំ ភញ្ជេយ្យ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ

១ ម. កុឋារឹ ។ ឱ. កុឋារឹ ។ ២ ម. អមុ យោ សោ ។



ផល់ផ្លែផង ការណ៍នោះ មានបុរសជាគំរប់ពីរ ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែ ត្រាច់ទៅស្វែងរកផ្លែ គឺកាន់យកនូវពូថៅដ៏មុតមកដល់ បុរសនោះចូលទៅកាន់ដងព្រៃនោះ ហើយឃើញនូវដើមឈើនោះ មានផ្លែផ្អែមផង មានផ្លែក្រអូមផង ទើបបុរសនោះគិតយ៉ាងនេះថា ឈើនេះឯង មានផ្លែផ្អែមផង មានផ្លែក្រអូមផង សូម្បីផ្លែណាមួយ គឺមិនជ្រុះចុះលើផែនដីឡើយ ឯអាត្មាអញ មិនចេះឡើងដើមឈើឡើយ បើដូច្នោះ មានតែអាត្មាអញកាប់ដើមឈើនេះត្រង់គល់ ហើយទំពាស៊ីតាមត្រូវការផង ដាក់ផ្លែផង បុរសនោះគិតហើយ ក៏កាប់ដើមឈើនោះត្រង់គល់ ម្ចាស់គហបតី អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសដែលឡើងដើមឈើមុននោះ បើមិនចុះមកដោយរហ័សទេ ដើមឈើនោះកាលរលំចុះ គប្បីបាក់ដៃ បំបាក់ជើង បំបាក់អវយវៈតូចធំណាមួយ របស់បុរសនោះ បុរសនោះ គប្បីដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះផ្លែឈើនោះជាហេតុ ថែមទៀត ។ ព្រះករុណាព្រះអង្គ ។ ម្ចាស់គហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា

រុក្ខផលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុ-
បាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថា-
ភូតំ សម្មប្បញ្ញាយ ទិស្វា យាយំ ឧបេក្ខា នានត្តា
នានត្តសិតា តំ អភិនិវជ្ជេត្វា យាយំ ឧបេក្ខា ឯកត្តា
ឯកត្តសិតា យត្ថ សព្វសោ លោកាមិសុបាទានា
អបរិសេសា និរុជ្ឈន្តិ តមេវ ឧបេក្ខំ ភាវេតិ ។

(៨៦) សោ ខោ សោ គហបតិ អរិយសាវកោ
ឥមំយេវ(១) អនុត្តរំ ឧបេក្ខាសតិបារិសុទ្ធឹ អាគម្ម
អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ
ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។បេ។ ឥតិ
សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុ-
ស្សរតិ ។ សោ ខោ សោ គហបតិ អរិយសាវកោ
ឥមំយេវ(២) អនុត្តរំ ឧបេក្ខាសតិបារិសុទ្ធឹ អាគម្ម ទិព្វេន
ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ
ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ
សុគតេ ទុគ្គតេ ។បេ។ យថាកម្មូបគេ សត្តេ បជា-
នាតិ ។ សោ ខោ សោ គហបតិ អរិយសាវកោ ឥមំ

១-២. ម. ឥមញ្ញេវ ។



កាមទាំងឡាយ មានឧបមាដោយផ្លែឈើ មានទុក្ខច្រើន មានសេចក្តី
ចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនេះ
ឯង អរិយសាវ័កឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ
ហើយ ក៏លះបង់នូវឧបេក្ខា ដែលមានសភាពផ្សេងគ្នា អាស្រ័យអារម្មណ៍
មានសភាពផ្សេងគ្នា ហើយចម្រើននូវឧបេក្ខា ដែលមានសភាពតែមួយ
អាស្រ័យអារម្មណ៍មានសភាពតែមួយ គឺឧបេក្ខាជាទីរលត់ទៅនៃឧបា-
ទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

(៨៦) ម្នាលគហបតី អរិយសាវ័កនោះឯង អាស្រ័យសេចក្តី
បរិសុទ្ធិនៃសតិ ដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយរលឹកនូវ
បុព្វេនិវាសច្រើនប្រការ គឺ រលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។
រលឹកនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការព្រមទាំងឧទ្ទេស ដោយ
ប្រការដូច្នេះ ។ ម្នាលគហបតី អរិយសាវ័កនោះឯង អាស្រ័យសេចក្តី
បរិសុទ្ធិនៃសតិ ដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយឃើញពួក
សត្វដែលច្យុត កើតឡើង ជាសត្វថោកទាប ឧត្តម មានវណ្ណៈល្អ មាន
វណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ ក៏ដឹងច្បាស់នូវពួក
សត្វ ដែលប្រព្រឹត្តទៅតាមកម្ម ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងវិស័យចក្ខុ
របស់មនុស្សសាមញ្ញ ។ ម្នាលគហបតី អរិយសាវ័កនោះឯង អាស្រ័យ